# ពង្រាងសំណើគម្រោងរបស់បុគ្គលិក លក្ខខណ្ឌតម្រូវការពិគ្រោះយោបល់និងការចូលរួមមុនដាក់ពាក្យសុំសម្រាប់ការកំណត់ទីតាំង និងការអនុញ្ញាត

## I. សេចក្តីផ្តើម

នៅខែវិច្ឆិកា ឆ្នាំ 2024 លោកអភិបាលក្រុង Healey បានអនុម័ត "ច្បាប់លើកកម្ពស់បណ្តាញថាមពលស្អាត ជំរុញសមធម៌ និងការពារអ្នកបង់ថ្លៃប្រើប្រាស់" ("ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024") ដែលគិតថ្លៃសេវាពីក្រុមប្រឹក្សាភិបាលកំណត់ទីតាំងបបនីយកណ្ឋថាមពល ("EFSB") ដោយចេញលិខិតអនុញ្ញាតរួមតែមួយ ដែលរួមបញ្ចូលរាល់លិខិតអនុញ្ញាតថ្នាក់រដ្ឋ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋានទាំងអស់ដែលតម្រូវឱ្យទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំទទួលបាន ដើម្បីចាប់ផ្តើមការសាងសង់ និងប្រតិបត្តិការ។ ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ក៏តម្រូវឱ្យនាយកដ្ឋានសេវាសាធារណៈរដ្ឋម៉ាសាឈូសិត ("DPU") រួមជាមួយនឹងក្រុមប្រឹក្សាភិបាល EFSB បង្កើតលក្ខខណ្ឌតម្រូវមុនដាក់ពាក្យសុំដែលអ្នកស្នើសុំត្រូវអនុវត្តតាម។ មើលច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ផ្នែក 74 (ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69T)។[1] ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 តម្រូវឱ្យអ្នកស្នើសុំផ្តល់ឱ្យក្រុមប្រឹក្សាភិបាល EFSB នូវភស្តុតាងបញ្ជាក់ការផ្សព្វផ្សាយដែលបានធ្វើឡើងមុនពេលដាក់ពាក្យស្នើសុំ។ ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ក៏ផ្តល់សិទ្ធិដល់ផ្នែកចូលរួមរបស់សាធារណជននៃនាយកដ្ឋាន DPU (ហៅកាត់ថា "DPP") ដែលទើបបង្កើតថ្មីឱ្យជួយភាគីពាក់ព័ន្ធក្នុងការស្វែងយល់អំពីលក្ខខណ្ឌតម្រូវការពិគ្រោះយោបល់និងការចូលរួមមុនដាក់ពាក្យសុំ ដោយសហការជាមួយការិយាល័យយុត្តិធម៌និងសមធម៌បរិស្ថាន ("OEJE") នៅការិយាល័យប្រតិបត្តិថាមពល និងកិច្ចការបរិស្ថាន) ("AEE")។[2] ពង្រាងសំណើគម្រោងរបស់បុគ្គលិកនេះ[3] ពិពណ៌នាអំពីលក្ខខណ្ឌតម្រូវមុនដាក់ពាក្យសុំដែលបានស្នើសម្រាប់ពាក្យសុំរបស់ក្រុមប្រឹក្សាភិបាល EFSB ។[4] ការធ្វើឱ្យលក្ខខណ្ឌតម្រូវមុនពេលដាក់ពាក្យសុំនេះមានលក្ខណៈផ្លូវការ បង្ហាញពី

[1] ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ក៏តម្រូវឱ្យម្ចាស់សំណើនៃ "ទីតាំងថាមពល" ចាស់ៗឱ្យអនុលោមតាមលក្ខខណ្ឌតម្រូវមុនដាក់ពាក្យសុំ។ មើលច្បាប់លក្ខន្តិកៈឆ្នាំ 2024 ជំពូក 239 ផ្នែក 65 (ច្បាប់ទូទៅឆ្នាំ ជំពូក 164 ផ្នែក 69J) និង 68 (ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69J¼ )។

[2] ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ក៏បង្កើតផងដែរនូវផ្នែកចូលរួមរបស់សាធារណជននៅក្នុងនាយកដ្ឋាន DPU។ ចំពោះបញ្ហាកំណត់ទីតាំងនិងការអនុញ្ញាតនៅក្រោមក្រុមប្រឹក្សាភិបាល EFSB ផ្នែកនេះភារកិច្ចជួយភាគីពាក់ព័ន្ធក្នុងការយល់ដឹងអំពីលក្ខខណ្ឌតម្រូវការពិគ្រោះយោបល់និងការចូលរួមមុនដាក់ពាក្យសុំ ការកំណត់ឱកាសក្នុងការចុះអន្តរាគមន៍ ការសម្របសម្រួលការសន្ទនារវាងភាគីពាក់ព័ន្ធទាក់ទងនឹងដំណើរការអនុញ្ញាត និងការជួយដល់ការសម្របសម្រួលជាមួយមន្ត្រីថ្នាក់រដ្ឋ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋានផ្សេងទៀត រួមទាំងការិយាល័យ OEJE ផ្នែកកិច្ចការ EEA ។

[3] "បុគ្គលិកក្រុមប្រឹក្សាភិបាល EFSB" សំដៅដល់បុគ្គលិករបស់ផ្នែកកំណត់ទីតាំងនៃនាយកដ្ឋាន DPU ។

[4] ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ក៏តម្រូវឱ្យនាយកដ្ឋានធនធានថាមពល ("DOER") ក្រោមការពិគ្រោះយោបល់ជាមួយនាយកដ្ឋាន DPU បង្កើតដំណើរការមុនពេលដាក់ពាក្យសុំដាច់ដោយឡែកមួយសម្រាប់ការអនុញ្ញាតរួមថ្នាក់មូលដ្ឋានរបស់ "ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូច" ដោយរដ្ឋាភិបាលមូលដ្ឋាន។ ច្បាប់ទូទៅ ជំពូក 30 ផ្នែក 21

ការផ្លាស់ប្តូរពីការអនុវត្តមុនដាក់ពាក្យសុំរបស់ក្រុមប្រឹក្សាភិបាល EFSB បច្ចុប្បន្ន ហើយឥឡូវនេះវារួមបញ្ចូលនូវការរំពឹងទុកនៃដំណើរការចូលរួមក្នុងសហគមន៍រឹងមាំដែលបានកំណត់។

ដំណើរការត្រួតពិនិត្យទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតរបស់ក្រុមប្រឹក្សាភិបាល EFSB នឹងទទួលបានអត្ថប្រយោជន៍ពីការផ្សព្វផ្សាយមុនពេលដាក់ពាក្យសុំ ដែលបង្កើតនូវឱកាសច្បាស់លាស់សម្រាប់ការចូលរួមពីភាគីពាក់ព័ន្ធប្រកបដោយអត្ថន័យ និងកំណត់យ៉ាងច្បាស់នូវការរំពឹងទុករបស់ភ្នាក់ងារសម្រាប់ម្ចាស់សំណើ។ ដំណើរការចូលរួមមុនពេលដាក់ពាក្យសុំគួរតែធានាថា សមាជិកសហគមន៍បានទទួលដំណឹងពេញលេញអំពីគម្រោងមួយនៅមុនការត្រួតពិនិត្យជាផ្លូវការរបស់ក្រុមប្រឹក្សាភិបាល EFSB អនុញ្ញាតឱ្យម្ចាស់សំណើកំណត់ពីក្តីកង្វល់ឱ្យបានឆាប់ និងអាចកែប្រែសំណើឱ្យឆ្លើយតបទៅនឹងតម្រូវការសហគមន៍។ ការចូលរួមមុនដាក់ពាក្យសុំឱ្យបានទាន់ពេលវេលា និងប្រកបដោយកិច្ចសហការជាមួយនឹងភ្នាក់ងារថ្នាក់មូលដ្ឋាននិងថ្នាក់រដ្ឋ ក៏នឹងកាត់បន្ថយឱកាសនៃភាពមិនស៊ីគ្នាដែលកើតឡើងរវាងការធ្វើផែនការហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ននិងអនាគត។ ដំណើរការផ្សព្វផ្សាយនិងការចូលរួមដ៏ជោគជ័យមុនពេលដាក់ពាក្យសុំ នឹងផ្តល់ឱកាសដើម្បីកាត់បន្ថយឧបសគ្គដែលអាចកើតឡើង មុនពេលធនធានកំណត់ទីតាំងដ៏សំខាន់ត្រូវបានផ្តល់ជូនដល់គម្រោងដែលបានស្នើ។

## II. <u>បរិការណ៍សម្រាប់ពង្រាងសំណើគម្រោង</u>

### A. <u>ការអនុវត្តហេដ្ឋារចនាសម្ព័ន្ធថាមពលដែលមានស្រាប់</u>

បច្ចុប្បន្ន គម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលអាចត្រូវបានត្រួតពិនិត្យដោយក្រុមប្រឹក្សាភិបាល EFSB ឬនាយកដ្ឋាន DPU ។ បច្ចុប្បន្ននេះ ក្រុមប្រឹក្សាភិបាល EFSB មិនមានលក្ខខណ្ឌតម្រូវការចូលរួមមុនពេលដាក់ពាក្យសុំជាផ្លូវការទេ ហើយគម្រោងដែលបានដាក់ជូនក្រុមប្រឹក្សាភិបាល EFSB ត្រូវឆ្លងកាត់សកម្មភាពមុនពេលដាក់ពាក្យសុំក្រៅផ្លូវការផ្សេងៗជាច្រើន។[5] មុនពេលអនុវត្តច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 សកម្មភាពត្រួតពិនិត្យការកំណត់ទីតាំងនិងការអនុញ្ញាតមួយចំនួនត្រូវបានចាត់ចែងជាចម្បងដោយនាយកដ្ឋាន DPU ដូចជាញត្តិសុំការលើកលែងការកំណត់តំបន់ និងការផ្លាស់ប្តូរ ឬការសាងសង់ថ្មីនៃខ្សែបញ្ជូនអគ្គិសនីរយៈចម្ងាយខ្លី។[6] ចំពោះបញ្ហាកំណត់ទីតាំងរបស់នាយកដ្ឋាន DPU ដែលត្រូវបានដាក់ជូនបន្ទាប់ពីខែសីហា ឆ្នាំ 2024 អ្នកដាក់ញត្តិស្នើសុំត្រូវចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយមុនដាក់ពាក្យសុំជាមួយសាធារណជន រួមទាំងមន្ត្រីក្រុង ក្រុមសហគមន៍ អាជីវកម្ម និងអ្នករស់នៅ ដែលជាផ្នែកមួយនៃដំណើរការមុនពេលស្នើសុំរបស់នាយកដ្ឋាន DPU ។[7] ឧទាហរណ៍ស្តីពីការផ្សព្វផ្សាយរបស់អ្នកដាក់ញត្តិ រួមមានការ

---

5 សកម្មភាពមុនពេលដាក់ពាក្យសុំ បានរួមបញ្ចូលនូវការជូនដំណឹងតាមសំបុត្រប្រៃសណីយ៍ ការចុះជួបតាមផ្ទះ ការជូនដំណឹងព្យួរតាមមាត់ទ្វារ គេហទំព័រគម្រោង ការជូនដំណឹងតាមអ៊ីម៉េល និងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយថ្នាក់ក្រុង។

6 ច្បាប់ស្តីពីបម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ផ្ទេរសិទ្ធិអំណាចក្នុងការកំណត់ទីតាំងរបស់នាយកដ្ឋាន DPU ទៅឱ្យក្រុមប្រឹក្សាភិបាល EFSB ត្រឹមថ្ងៃទី 1 ខែមីនា ឆ្នាំ 2026 ជាមួយនឹងធាតុផ្សំមួយចំនួន (ដូចជាការលើកលែងការកំណត់តំបន់ជាដើម លើកលែងតែនៅទីក្រុង Boston) ដែលបានផ្ទេរត្រឹមថ្ងៃទី 18 ខែកុម្ភៈ ឆ្នាំ 2025។

7 សម្រាប់ការត្រួតពិនិត្យការកំណត់ទីតាំងរបស់នាយកដ្ឋាន DPU ត្រូវអនុវត្តតាមគោលនយោបាយកំណត់ចំណាត់ថ្នាក់គម្រោង និងការផ្សព្វផ្សាយរបស់នាយកដ្ឋាន DPU ។ <u>មើល</u> D.P.U. 21-50-A អាចស្វែងរកបានតាមរយៈ https://fileservice.eea.comacloud.net/FileService.Api/file/FileRoom/18651202.

ផ្សព្វផ្សាយតាមផ្ទះនៅតាមទីតាំងអចលនទ្រព្យដែលនៅជាប់នឹងផ្លូវ ការរៀបចំព្រឹត្តិការណ៍កម្មវិធីចុះតាមផ្ទះនិងសាកសួរព័ត៌មានដោយប្រើប្រាស់ឯកសារបោះពុម្ពច្រើនភាសា និងសេវាកម្មបកប្រែប្រដេញផ្ទាល់មាត់ និងការផ្សព្វផ្សាយតាមរយៈការផ្សាយពាណិជ្ជកម្មតាមកាសែត គេហទំព័រគម្រោង -អ៊ីម៉េល និងសារាចរណែនាំ។ ការពិភាក្សារវាងម្ចាស់សំណើគម្រោង និងភាគីពាក់ព័ន្ធ រួមមានព័ត៌មានអំពីផ្លូវខ្សែបញ្ជូនអគ្គិសនី វិធីភ្ជាប់កម្មវិធីដើម្បីទទួលបានការជូនដំណឹងអំពីគម្រោង និងការចូលរួមក្នុងកិច្ចប្រជុំ "ចុះតាមផ្ទះ" ដែលរៀបចំដោយម្ចាស់សំណើ។ ម្ចាស់សំណើតែងផ្តល់ព័ត៌មានដល់ភាគីពាក់ព័ន្ធអំពីតម្រូវការគម្រោង ការពិចារណាលើការរចនាប្លង់ និងដំណើរការអនុញ្ញាតនិងកាលវិភាគសម្រាប់គម្រោង។

ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលជាច្រើនដែលបានពិនិត្យដោយក្រុមប្រឹក្សាភិបាល EFSB ក៏ត្រូវតែបានពិនិត្យដោយការិយាល័យច្បាប់គោលនយោបាយបរិស្ថានរដ្ឋម៉ាសាឈូសិត (“MEPA”) ដែលបានបង្កើតលក្ខខណ្ឌតម្រូវមុនដាក់ពាក្យសុំសម្រាប់ប្រជាជនយុត្តិធម៌បរិស្ថាន[8]។ ដូច្នេះ មានវិធានការមួយចំនួននៃលក្ខខណ្ឌតម្រូវមុនដាក់ពាក្យសុំដែលម្ចាស់សំណើត្រូវតែអនុវត្តឱ្យបានរួចរាល់។ ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 បង្ហាញនូវឱកាសកែលម្អលក្ខខណ្ឌតម្រូវការផ្សព្វផ្សាយមុនដាក់ពាក្យសុំសម្រាប់ម្ចាស់សំណើគម្រោង ដែលនឹងធានាថាបុគ្គលដែលអាចរងផលប៉ះពាល់ និងភ្នាក់ងារថ្នាក់រដ្ឋនិងថ្នាក់មូលដ្ឋាន ទទួលបានព័ត៌មានគម្រោងមុនកាលកំណត់ និងអាចមានឥទ្ធិពលលើការកំណត់ទីតាំង និងការរចនាប្លង់គម្រោង។

B. <u>ធនធានគន្លឹះដែលបានពិគ្រោះក្នុងការបង្កើតលក្ខខណ្ឌតម្រូវមុនដាក់ពាក្យសុំដែលបានស្នើ</u>

ដើម្បីបង្កើតពង្រាងសំណើគម្រោងនេះ បុគ្គលិកបានពិនិត្យមើលលក្ខខណ្ឌតម្រូវមុនដាក់ពាក្យសុំរបស់នាយកដ្ឋាន DPU លក្ខខណ្ឌតម្រូវរបស់ MEPA អនុសាសន៍របស់គណៈកម្មការកំណត់ទីតាំងនិងអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធថាមពល ("CEISP") និងលក្ខខណ្ឌតម្រូវមុនដាក់ពាក្យសុំនៅ New York, California, Maine, Michigan, New Hampshire, Vermont, Ohio, Virginia, North Carolina និង Kentucky ។ បុគ្គលិកនាយកដ្ឋាន DPU និងក្រុមប្រឹក្សាភិបាល EFSB ក៏កំពុងពិគ្រោះយោបល់ជាមួយទីភ្នាក់ងារអនុញ្ញាត ដែលនឹងចេញលិខិតអនុញ្ញាត ដើម្បីទទួលបានមតិចូលរួមរបស់ពួកគេស្របតាមលក្ខខណ្ឌតម្រូវសកម្មភាពមុនដាក់ពាក្យសុំ។

C. <u>វត្ថុបំណងសម្រាប់លក្ខខណ្ឌតម្រូវការចូលរួមមុនដាក់ពាក្យសុំ</u>

ការផ្សព្វផ្សាយរបស់ម្ចាស់សំណើគម្រោងបានប្រែប្រួលយ៉ាងខ្លាំងនាពេលកន្លងមក។ ជាពិសេស ការផ្សព្វផ្សាយគម្រោងអាចនឹងកើតមាននៅពេលក្រោយក្នុងដំណើរការអភិវឌ្ឍន៍ នៅពេលដែលមានការលំបាកក្នុងការធ្វើការផ្លាស់ប្តូរសំខាន់ៗចំពោះគម្រោង។ អ្នកផ្តល់យោបល់សាធារណៈជារឿយៗបញ្ជាក់ថា ពួកគេទើបតែបានដឹងអំពីគម្រោងនាពេលថ្មីៗនេះតែប៉ុណ្ណោះ ថាគម្រោងនោះត្រូវបានបង្កើតឡើងរយៈពេលជាច្រើនឆ្នាំមកហើយ។ ដើម្បីដោះស្រាយភាពមិនស្របគ្នាទាំងនេះ បុគ្គលិកបានបង្កើតវត្ថុបំណងដូចខាងក្រោមសម្រាប់លក្ខខណ្ឌតម្រូវការចូលរួមមុនដាក់ពាក្យសុំ៖

1. បង្កើតលក្ខខណ្ឌតម្រូវមុនដាក់ពាក្យសុំរបស់ក្រុមប្រឹក្សាភិបាល EFSB ដើម្បីធានាបាននូវភាពស៊ីសង្វាក់គ្នាក្នុងការអនុវត្តការផ្សព្វផ្សាយគ្រប់គម្រោងទាំងអស់ និងផ្តល់ឱកាសសម្រាប់ការចូលរួមរបស់សាធារណជន។

8 https://www.mass.gov/doc/final-mepa-public-involvement-protocol-for-environmental-justice-populations-effective-date-of-january-1-2022/download.

2. ធានាថាព័ត៌មានអំពីគម្រោងផ្សព្វផ្សាយដល់បុគ្គល និងអង្គភាពពាក់ព័ន្ធ ដែលពួកគេអាចរងផលប៉ះពាល់ដោយការសាងសង់ ឬប្រតិបត្តិការគម្រោង ព្រមទាំងទីភ្នាក់ងាររដ្ឋ និងមូលដ្ឋានផងដែរ។
3. ផ្តល់ឱកាសដើម្បីឱ្យភាគីពាក់ព័ន្ធសំខាន់ៗមានឥទ្ធិពលលើការរចនាប្លង់គម្រោងក្នុងដំណាក់កាលសំខាន់នៃការអភិវឌ្ឍគម្រោង និង
4. ធានាថាគម្រោងនានាស្របតាមគោលនយោបាយផែនការរយៈពេលវែងរបស់រដ្ឋនិងក្រុង និងរួមចំណែកដល់គោលដៅអាកាសធាតុ និងសមធម៌របស់រដ្ឋម៉ាសាឈូសិត។

D. <u>ការសហការរបស់ទីភ្នាក់ងារ</u>

ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 តម្រូវឱ្យនាយកដ្ឋាន DOER ក្រោមការពិគ្រោះយោបល់ជាមួយនាយកដ្ឋាន DPU បង្កើតដំណើរការមុនដាក់ពាក្យសុំសម្រាប់ការកំណត់ទីតាំង និងការអនុញ្ញាតឱ្យ “ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូច” តាមរយៈរដ្ឋាភិបាលមូលដ្ឋាន។[9] ក្រុមប្រឹក្សាភិបាល EFSB និងនាយកដ្ឋាន DPU នឹងពិគ្រោះយោបល់ជាមួយនាយកដ្ឋាន DOER ដើម្បីធានាបាននូវភាពស៊ីសង្វាក់គ្នារវាងលក្ខខណ្ឌតម្រូវដែលបានបង្កើតឡើងដោយភ្នាក់ងារទាំងពីរនៅពេលសមស្រប។ ក្រុមប្រឹក្សាភិបាល EFSB និងនាយកដ្ឋាន DPU ក៏នឹងពិគ្រោះយោបល់ជាមួយការិយាល័យ MEPA ដែលមានបទពិសោធន៍ទូលំទូលាយក្នុងការវាយតម្លៃផលប៉ះពាល់បរិស្ថាននៃគម្រោង បញ្ហាដីធ្លី និងវិធានការកាត់បន្ថយផលប៉ះពាល់។ ពិតមែនតែច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 លុបចោលការត្រួតពិនិត្យរបស់ MEPA ដែលជាលក្ខខណ្ឌតម្រូវមួយសម្រាប់ការពិនិត្យឡើងវិញនូវទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតទាំងអស់ (ឧ. ការត្រួតពិនិត្យការអនុញ្ញាតរួមរបស់ក្រុមប្រឹក្សាភិបាល EFSB ឬការត្រួតពិនិត្យការអនុញ្ញាតរួមថ្នាក់មូលដ្ឋាន) យ៉ាងណាក្តី ប៉ុន្តែវាតម្រូវឱ្យមានការពិគ្រោះយោបល់មុនដាក់ពាក្យសុំជាមួយនឹងភ្នាក់ងារផ្តល់ការអនុញ្ញាតផ្សេងទៀត រួមទាំងការិយាល័យ MEPA ផងដែរ។[10,11]

## III. <u>ការពិភាក្សាអំពីសមាសធាតុពង្រាងសំណើគម្រោងសំខាន់ៗ</u>

ពង្រោងសំណើគម្រោងនេះពិចារណាលើលក្ខខណ្ឌតម្រូវសម្រាប់ពេលវេលា និងវិធីដែលទីក្រុង សមាជិកសហគមន៍ និងទីភ្នាក់ងាររដ្ឋដែលអាចរងផលប៉ះពាល់ ទទួលបានដំណឹងអំពី

---

9. ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 បន្ថែមលក្ខខណ្ឌមួយ "ដែលធ្វើឱ្យមានស្តង់ដាលក្ខខណ្ឌតម្រូវមុនដាក់ពាក្យសុំសម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូច ដែលនឹងរួមបញ្ចូលលក្ខខណ្ឌតម្រូវជាក់លាក់សម្រាប់ការប្រជុំសាធារណៈ និងទម្រង់នៃការផ្សព្វផ្សាយផ្សេងទៀតដែលត្រូវតែប្រព្រឹត្តទៅមុនពេលអ្នកដាក់ពាក្យសុំប្រគល់ជូនពាក្យសុំ" ។ ច្បាប់ទូទៅ ជំពូក 30 ផ្នែក 21

10 ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ដឹកនាំការបង្កើត “លក្ខខណ្ឌតម្រូវមុនដាក់ពាក្យសុំស្របនឹងវិសាលភាព និងមាត្រដ្ឋានទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតដែលបានស្នើ ដែលនឹងរួមបញ្ចូលនូវលក្ខខណ្ឌតម្រូវជាក់លាក់សម្រាប់ការពិគ្រោះយោបល់មុនដាក់ពាក្យសុំជាមួយភ្នាក់ងារអនុញ្ញាត និង [ការិយាល័យ MEPA] ការប្រជុំសាធារណៈ និងទម្រង់នៃការផ្សព្វផ្សាយផ្សេងទៀតដែលត្រូវតែប្រព្រឹត្តទៅនៅមុនពេលអ្នកស្នើសុំប្រគល់ជូនពាក្យសុំ...” ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69T(b)(iii)។

11 ច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ក៏តម្រូវឱ្យក្រុមប្រឹក្សាភិបាល EFSB បង្កើត "ស្តង់ដាសម្រាប់ការអនុវត្តស្តង់ដា និងគោលការណ៍ណែនាំស្តីពីការវិភាគលើផលប៉ះពាល់ដែលបង្កើតឡើងដោយការិយាល័យយុត្តិធម៌និងសមធម៌បរិស្ថាន អនុលោមតាមផ្នែក 29 នៃជំពូក 21A"។ ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69T

គម្រោងដែលបានស្នើឡើង ព័ត៌មានគម្រោងដែលបានជម្រាបប្រាប់ និងពិធីសារចូលប្រើភាសាដែលអ្នកស្នើអាចនឹងអនុវត្តតាម ដើម្បីបង្កើនការចូលរួមជាសាធារណៈប្រកបដោយអត្ថន័យ គាំទ្រកិច្ចពិភាក្សា និងជូនដំណឹងដល់ភាគីពាក់ព័ន្ធអំពីគម្រោងដែលបានស្នើឡើង។ សំណើនេះរួមបញ្ចូលផ្នែកនានាដូចខាងក្រោម៖

A. លក្ខខណ្ឌតម្រូវការផ្សព្វផ្សាយមុនដាក់ពាក្យសុំ
   1. លក្ខខណ្ឌតម្រូវការផ្សព្វផ្សាយមុនដាក់ពាក្យសុំដំណាក់កាលទី 1
   2. លក្ខខណ្ឌតម្រូវការផ្សព្វផ្សាយមុនដាក់ពាក្យសុំដំណាក់កាលទី 2

B. ការជូនដំណឹងមុនដាក់ពាក្យសុំអំពីបំណងក្នុងការដាក់ពាក្យសុំ

C. ឯកសារដែលត្រូវដាក់ជូន (ដាក់ឯកសារ) រួមជាមួយនឹងការជូនដំណឹងមុនដាក់ពាក្យសុំ

## A. លក្ខខណ្ឌតម្រូវការផ្សព្វផ្សាយមុនដាក់ពាក្យសុំ

ពង្រាងសំណើគម្រោងនេះគូសបញ្ជាក់ពីលក្ខខណ្ឌតម្រូវការផ្សព្វផ្សាយមុនដាក់ពាក្យសុំ សម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំដែលស្ថិតនៅក្រោមយុត្តាធិការរបស់ក្រុមប្រឹក្សាភិបាល EFSB និងទីតាំងហេដ្ឋារចនាសម្ព័ន្ធបញ្ជូន ចែកចាយ បង្កើត ឬរក្សាទុកថាមពលស្អាតខ្នាតតូច ដែលជ្រើសរើសស្វែងរកលិខិតអនុញ្ញាតរួមពីក្រុមប្រឹក្សាភិបាល EFSB [12]។ លក្ខខណ្ឌតម្រូវការផ្សព្វផ្សាយមុនដាក់ពាក្យសុំ នឹងប្រព្រឹត្តទៅជាពីរដំណាក់កាល។ តម្រូវឱ្យម្ចាស់សំណើពិចារណាយ៉ាងដិតដល់ និងរួមបញ្ចូលមតិកែលម្អរបស់ភាគីពាក់ព័ន្ធ ចាប់ពីការរៀបចំផែនការគម្រោងដំណាក់កាលដំបូង រហូតដល់ការជ្រើសរើសយកជម្រើសផ្លូវ ឬទីតាំងតាមការចង់បាន មុនពេលម្ចាស់សំណើដាក់ពាក្យស្នើសុំទៅកាន់ក្រុមប្រឹក្សាភិបាល EFSB ។ ការផ្សព្វផ្សាយមុនដាក់ពាក្យសុំក៏នឹងរួមបញ្ចូលការពិគ្រោះយោបល់ជាមួយភ្នាក់ងារអនុញ្ញាតរដ្ឋនិងមូលដ្ឋាន ដែលមានកម្មវិធីនិយតកម្មដែលជះឥទ្ធិពលដល់គម្រោងជាក់លាក់ណាមួយ។

ការផ្សព្វផ្សាយដំណាក់កាលទី 1 នឹងជូនដំណឹង និងស្វែងរកមតិកែលម្អពីភាគីពាក់ព័ន្ធក្នុងមូលដ្ឋាន ដូចជាអ្នករស់នៅជាប់ទីតាំង មន្ត្រីក្រុង ទីភ្នាក់ងារអនុញ្ញាតរបស់រដ្ឋ (សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំ) និងក្រុមសហគមន៍សំខាន់ៗដែលអាចរងផលប៉ះពាល់ពីគម្រោងនេះ។ ការផ្សព្វផ្សាយដំណាក់កាលទី 2 នឹងរួមបញ្ចូលការផ្សព្វផ្សាយព័ត៌មានគម្រោងទៅកាន់ភាគីពាក់ព័ន្ធដំណាក់កាលទី 1 និងសហគមន៍ទូទៅ ដោយប្រើបណ្ដាញផ្សព្វផ្សាយចម្រុះ។ លើសពីនេះ ម្ចាស់សំណើគម្រោងនឹងរៀបចំកិច្ចប្រជុំសាធារណៈចំនួនពីរក្នុងដំណាក់កាលទី 2 ដើម្បីស្វែងរកមតិចូលរួមស្ដីអំពីផ្លូវនិងទីតាំងដ៏មានសក្ដានុពលដែលកំពុងពិចារណា។

លក្ខខណ្ឌតម្រូវផ្សព្វផ្សាយមុនដាក់ពាក្យសុំ ត្រូវបានរៀបចំឡើងដើម្បីអនុញ្ញាតឱ្យភាគីពាក់ព័ន្ធសំខាន់ៗ និងសហគមន៍ទូទៅមានឥទ្ធិពលលើការរចនាគម្រោង រួមទាំងការជ្រើសរើសផ្លូវ និង/ឬទីតាំង។ ម្ចាស់សំណើគម្រោងនឹងតម្រូវឱ្យកំណត់ពេលប្រជុំរៀបចំមុនដាក់ពាក្យសុំជាមួយនាយកដ្ឋាន DPP និងការិយាល័យ OEJE ដើម្បីពិភាក្សាអំពីគម្រោងដែលបានស្នើ បញ្ជាក់ព័ត៌មាន និងតម្រូវការឯកសារ និងបញ្ជាក់ពីការផ្សព្វផ្សាយដែលត្រូវប្រព្រឹត្តទៅមុនពេលដាក់ពាក្យស្នើសុំទៅកាន់ក្រុមប្រឹក្សាភិបាល EFSB ។

---

12 ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69U អនុញ្ញាតឱ្យម្ចាស់សំណើនៃទីតាំង ហេដ្ឋារចនាសម្ព័ន្ធបញ្ជូននិងចែកចាយថាមពលស្អាតខ្នាតតូច (SCT&D) ជ្រើសរើសស្វែងរកលិខិតអនុញ្ញាតរួមពីក្រុមប្រឹក្សាភិបាល EFSB ដែលរួមបញ្ចូលលិខិតអនុញ្ញាតចាំបាច់ថ្នាក់រដ្ឋ ថ្នាក់មូលដ្ឋាន និងថ្នាក់តំបន់ទាំងអស់។ ច្បាប់ទូទៅ ជំពូក 164 ផ្នែក 69V អនុញ្ញាតឱ្យម្ចាស់សំណើនៃទីតាំងបង្កើតថាមពលស្អាតខ្នាតតូច (SCEG) និងទីតាំងផ្ទុកថាមពលស្អាតខ្នាតតូច (SCES) ជ្រើសរើសស្វែងរកលិខិតអនុញ្ញាតរួមថ្នាក់រដ្ឋពីក្រុមប្រឹក្សាភិបាល EFSB ដែលរួមបញ្ចូលការអនុញ្ញាតចាំបាច់ថ្នាក់រដ្ឋទាំងអស់។

តារាងខាងក្រោមនេះផ្តល់នូវទិដ្ឋភាពទូទៅនៃពេលវេលា និងរយៈពេលនៃលក្ខខណ្ឌតម្រូវផ្សព្វផ្សាយមុនដាក់ពាក្យសុំដំណាក់កាលទី 1 និងដំណាក់កាលទី 2 សម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំនិងខ្នាតតូច ដែលស្វែងរកលិខិតអនុញ្ញាតរួមពីក្រុមប្រឹក្សាភិបាល EFSB ។

| ដំណាក់កាល | លក្ខខណ្ឌតម្រូវការផ្សព្វផ្សាយមុនដាក់ពាក្យសុំសម្រាប់ម្ចាស់សំណើ | ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំ | | ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូច | |
|---|---|---|---|---|---|
| | | ពេលវេលា | រយៈពេល | ពេលវេលា | រយៈពេល |
| ដំណាក់កាលទី 1 | ជួបជាមួយផ្នែក DPP & ការិយាល័យ OEJE ដើម្បីបញ្ជាក់ការផ្សព្វផ្សាយ និងបញ្ជាក់ពីតម្រូវការឯកសារ | យ៉ាងហោចណាស់ 12 ខែ មុនការជូនដំណឹងមុនដាក់ពាក្យសុំជាមួយក្រុមប្រឹក្សាភិបាល EFSB | គ្មាន | យ៉ាងហោចណាស់ 9 ខែ មុនការជូនដំណឹងមុនដាក់ពាក្យសុំជាមួយក្រុមប្រឹក្សាភិបាល EFSB | គ្មាន |
| | ពិគ្រោះជាមួយ MEPA និងភ្នាក់ងារអនុញ្ញាតថ្នាក់រដ្ឋនិងថ្នាក់មូលដ្ឋានតាមការសមស្រប | ចាប់ផ្តើមយ៉ាងហោចណាស់ 12 ខែមុនការជូនដំណឹងមុនដាក់ពាក្យសុំជាមួយក្រុមប្រឹក្សាភិបាល EFSB | យ៉ាងតិច 3 ខែ | មិនតម្រូវឱ្យមានការពិគ្រោះយោបល់ជាមួយ MEPA ទេ។ | យ៉ាងតិច 3 ខែ |
| | ពិចារណាលើលក្ខណៈវិនិច្ឆ័យភាពសមស្របនៃទីតាំង EEA និងការណែនាំអំពីការវិភាគផលប៉ះពាល់ជារួម | | | ចាប់ផ្តើមយ៉ាងហោចណាស់ 9 ខែមុនការជូនដំណឹងមុនដាក់ពាក្យសុំជាមួយក្រុមប្រឹក្សាភិបាល EFSB | |
| | ជួបជាមួយភាគីពាក់ព័ន្ធសំខាន់ៗ រួមមានមន្ត្រីក្រុង អ្នករស់នៅជាប់ទីតាំងគម្រោងជាសក្តានុពល និងក្រុមសហគមន៍ | | | | |
| | ដាក់ជូនតារាងផ្ទៀងផ្ទាត់ការបញ្ចប់ការផ្សព្វផ្សាយដំណាក់កាលទី 1 ដែលខ្លួនបានបញ្ជាក់ត្រឹមត្រូវទៅកាន់ផ្នែក DPP និងធ្វើបច្ចុប្បន្នភាពគេហទំព័រគម្រោងជាមួយនឹងព័ត៌មានផ្សព្វផ្សាយដំណាក់កាលទី 1 | បង្ហាញពីការបញ្ចប់ការផ្សព្វផ្សាយដំណាក់កាលទី 1 | | បង្ហាញពីការបញ្ចប់ការផ្សព្វផ្សាយដំណាក់កាលទី 1 | |
| ដំណាក់កាលទី 2 | បង្ហាញពីកិច្ចខិតខំប្រឹងប្រែងជូនដំណឹង ចូលរួម និងសហការជាដៃគូជាមួយអង្គការសហគមន៍ មន្ត្រីរដ្ឋ និងមន្ត្រីក្រុង | អំឡុងពេលផ្សព្វផ្សាយដំណាក់កាលទី 2 | 9 ខែ | អំឡុងពេលផ្សព្វផ្សាយដំណាក់កាលទី 2 | 6 ខែ |
| | ផ្សព្វផ្សាយព័ត៌មានគម្រោងដោយប្រើបណ្តាញផ្សព្វផ្សាយចម្រុះ។ | | | | |
| | បន្តផ្តល់ព័ត៌មានថ្មីៗនៅលើគេហទំព័រគម្រោង | | | | |
| | រៀបចំការប្រជុំសាធារណៈលើកដំបូង | ជិតចាប់ផ្តើមដំណាក់កាលទី 2 | | ជិតចាប់ផ្តើមដំណាក់កាលទី 2 | |
| | ធ្វើការពិគ្រោះយោបល់លើកទីពីរជាមួយ MEPA និងភ្នាក់ងារអនុញ្ញាតរបស់រដ្ឋ និងមូលដ្ឋាន | បន្ទាប់ពីកិច្ចប្រជុំសាធារណៈលើកទីមួយ | | បន្ទាប់ពីកិច្ចប្រជុំសាធារណៈលើកទីមួយ | |
| | ប្រគល់ការជូនដំណឹងមុនដាក់ពាក្យសុំជូនដល់ក្រុមប្រឹក្សាភិបាល EFSB | មិនតិចជាង 90 ថ្ងៃ និងមិនលើសពី 120 ថ្ងៃមុនពេលដាក់ពាក្យស្នើសុំគម្រោង | 3 ខែ | មិនតិចជាង 90 ថ្ងៃមុនពេលដាក់ពាក្យស្នើសុំគម្រោង | 3 ខែ |
| | រៀបចំកិច្ចប្រជុំសាធារណៈលើកទីពីរ | យ៉ាងហោចណាស់ 45 ថ្ងៃ មុនដាក់ពាក្យស្នើសុំគម្រោងទៅកាន់ក្រុមប្រឹក្សាភិបាល EFSB | | យ៉ាងហោចណាស់ 45 ថ្ងៃ មុនដាក់ពាក្យស្នើសុំគម្រោងទៅកាន់ក្រុមប្រឹក្សាភិបាល EFSB | |
| | រយៈពេលមតិយោបល់សាធារណៈបើកចំហ | ចាប់ពីការប្រជុំជាសាធារណៈលើកទីមួយរហូតដល់ 30 ថ្ងៃ មុនការជូនដំណឹងមុនដាក់ពាក្យសុំជាមួយក្រុមប្រឹក្សាភិបាល EFSB | | ចាប់ពីការប្រជុំជាសាធារណៈលើកទីមួយរហូតដល់ 30 ថ្ងៃ មុនការជូនដំណឹងមុនដាក់ពាក្យសុំជាមួយក្រុមប្រឹក្សាភិបាល EFSB | |
| | ប្រគល់តារាងត្រួតពិនិត្យការផ្សព្វផ្សាយដំណាក់កាលទី 2 ដែលខ្លួនបញ្ជាក់ត្រឹមត្រូវជូនដល់ផ្នែក DPP | បង្ហាញពីការបញ្ចប់ការផ្សព្វផ្សាយដំណាក់កាលទី 2 | | បង្ហាញពីការបញ្ចប់ការផ្សព្វផ្សាយដំណាក់កាលទី 2 | |

1. <u>លក្ខខណ្ឌតម្រូវការផ្សព្វផ្សាយមុនដាក់ពាក្យសុំដំណាក់កាលទី 1</u>

ការផ្សព្វផ្សាយដំណាក់កាលទី 1 នឹងប្រព្រឹត្តទៅនៅដើមដំបូងក្នុងអំឡុងពេលធ្វើផែនការគម្រោង នៅពេលដែលផ្លូវនិងទីតាំងដ៏មានសក្តានុពលជាច្រើនកំពុងស្ថិតក្រោមការពិចារណាសម្រាប់គម្រោងដែលបានស្នើឡើង។ ជាផ្នែកមួយនៃដំណាក់កាលទី 1 នេះ ម្ចាស់សំណើគម្រោងនឹងត្រូវពិនិត្យមើលលក្ខណៈវិនិច្ឆ័យភាពសមស្របនៃទីតាំង និងការណែនាំអំពីការវិភាគផលប៉ះពាល់ដែល EEA បានរៀបរាងឡើងដោយមានគោលដៅកំណត់ផ្លូវនិងទីតាំងសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត ដែលជៀសវាង ឬកាត់បន្ថយផលប៉ះពាល់ និងកាត់បន្ថយលទ្ធភាពកើតមានផលប៉ះពាល់អវិជ្ជមានមិនសមស្របនានា។ ម្ចាស់សំណើនឹងតម្រូវឱ្យពិគ្រោះជាមួយ MEPA និងភ្នាក់ងារអនុញ្ញាតរបស់រដ្ឋនិងមូលដ្ឋានទាំងអស់ដែលម្ចាស់សំណើបានកំណត់ដើម្បីទទួលបានមតិកែលម្អលើការអនុលោមតាមលក្ខខណ្ឌតម្រូវបទប្បញ្ញត្តិ និងឧត្តមានុវត្តផ្សេងទៀត ដើម្បីជៀសវាង ឬកាត់បន្ថយផលប៉ះពាល់ ក៏ដូចជាទទួលបានអនុសាសន៍សម្រាប់ការសិក្សាឬការវិភាគបែបវិទ្យាសាស្ត្រដែលអាចនឹងចាំបាច់ក្នុងការផ្តល់ព័ត៌មានដល់ការពិនិត្យគម្រោងរបស់ទីភ្នាក់ងារនៅពេលដាក់ជូនគម្រោងនោះទៅកាន់ក្រុមប្រឹក្សាភិបាល EFSB ។ ផ្អែកតាមលក្ខណៈនៃគម្រោង ទីភ្នាក់ងារ MEPA អាចណែនាំបន្ថែមដល់ទីភ្នាក់ងាររដ្ឋ ឬភ្នាក់ងារសហព័ន្ធដែលម្ចាស់សំណើគួរតែពិគ្រោះយោបល់ក្នុងអំឡុងពេលផ្សព្វផ្សាយដំណាក់កាលទី 1 ។ ដើម្បីជួយសម្រួលដល់ការពិគ្រោះយោបល់មុនដាក់ពាក្យសុំ ម្ចាស់សំណើតម្រូវឱ្យរៀបចំព័ត៌មានលម្អិតអំពីគម្រោងជាមូលដ្ឋាន ដើម្បីបង្ហាញដល់ MEPA និងទីភ្នាក់ងារផ្សេងទៀត រួមទាំងការពិពណ៌នាអំពីសកម្មភាពការងារដែលបានស្នើឡើង, ផ្លូវ/ទីតាំងដ៏មានសក្តានុពលសម្រាប់គម្រោង និងជម្រើសគម្រោងផ្សេងទៀតដែលស្ថិតក្រោមការពិចារណា, ការពិភាក្សាអំពីវិធីសាស្ត្រដែលគម្រោងបំពេញតាមលក្ខណៈវិនិច្ឆ័យភាពសមស្របនៃទីតាំង និងការណែនាំអំពីការវិភាគផលប៉ះពាល់សម្រាប់ការកំណត់ទីតាំងថាមពល, បញ្ជីរាយនាមលិខិតអនុញ្ញាតថ្នាក់មូលដ្ឋាន ថ្នាក់រដ្ឋ និងថ្នាក់សហព័ន្ធចាំបាច់ទាំងអស់, និងបញ្ជី/ផែនទីទីតាំងដែលបង្ហាញពីទីតាំងគម្រោងដែលបានរំពឹងទុក និងឧបសគ្គផ្នែកធនធានបរិស្ថានដែលពាក់ព័ន្ធ (ឧ. មាត្រា 97៖ ដីធ្លី ដីសើម, ច្បាប់ទូទៅជំពូក 91៖ ព្រំប្រទល់, ជម្រកប្រភេទសត្វកម្រ, តំបន់ដែលជាក្តីកង្វល់ខ្លាំងចំពោះបរិស្ថាន (ACEC) ។ល។)។ ចំនួនប្រជាជនយុត្តិធម៌បរិស្ថាន ("EJ") ក្នុងរយៈចម្ងាយមួយម៉ាយល៍នៃទីតាំងដែលបានស្នើនីមួយៗ គួរតែត្រូវបានកំណត់ផងដែរ។ ការពិគ្រោះយោបល់ដំណាក់កាលទី 1 ជាមួយ MEPA គឺមិនចាំបាច់សម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូចដែលស្វែងរកលិខិតអនុញ្ញាតរួមពីក្រុមប្រឹក្សាភិបាល EFSB ទេ។

ក្នុងដំណាក់កាលទី 1 ម្ចាស់សំណើនឹងធ្វើការផ្សព្វផ្សាយតាមគោលដៅជាទម្រង់ដាច់ដោយឡែក ក៏ដូចជាការពិភាក្សារួមគ្នាជាមួយភាគីពាក់ព័ន្ធសំខាន់ៗ មានជាអាទិ៍ អ្នករស់នៅជាប់នឹងគម្រោងដ៏មានសក្តានុពល (ទាំងម្ចាស់កម្មសិទ្ធិ និងអ្នកជួល) និងអាជីវកម្ម ក្រុមសហគមន៍ និងមន្ត្រីក្រុងដែលបានជ្រើសរើសឬជ្រើសតាំង (ឧ. អភិបាលក្រុង ឬអ្នកគ្រប់គ្រងក្រុង/ទីប្រជុំជន) សមាជិកក្រុមប្រឹក្សា/ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធ ប្រធានគណៈកម្មាធិការអភិរក្ស ក្រុមប្រឹក្សាផែនការ ក្រុមប្រឹក្សាតំបន់ និងជាប្រធាននាយកដ្ឋានសាធារណការ)។

នៅក្នុងកិច្ចប្រជុំភាគីពាក់ព័ន្ធនីមួយៗ ម្ចាស់សំណើគម្រោងនឹងពិភាក្សាអំពីផ្លូវ និង/ឬទីតាំងដែលមានសក្តានុពលទាំងអស់ដែលកំពុងពិចារណា រួមជាមួយនឹងការពិពណ៌នាអំពីគម្រោង តម្រូវការឬគោលបំណងនៃគម្រោង ការប្រៀបធៀបទូទៅនៃផលប៉ះពាល់ដែលរំពឹងទុកអំពីផ្លូវ/ទីតាំងដ៏មានសក្តានុពលនីមួយៗ និងជម្រើសគម្រោងផ្សេងទៀត កាលវេលាប៉ាន់ស្មានសម្រាប់ការដាក់ពាក្យស្នើសុំទៅកាន់ក្រុមប្រឹក្សាភិបាល EFSB និងឱកាសនាពេលអនាគតសម្រាប់មតិសាធារណៈ ឬមតិចូលរួមស្តីពីគម្រោងនេះ។ ម្ចាស់សំណើគម្រោងនឹងតម្រូវឱ្យបញ្ជាក់ និងរៀបចំសម្រាប់ការបកប្រែផ្ទាល់មាត់ និង/ឬឯកសារបកប្រែតាមការស្នើសុំរបស់អ្នកចូលរួមនៅក្នុងកិច្ចប្រជុំដំណាក់កាលទី 1។ បន្ទាប់ពីការផ្សព្វផ្សាយដំណាក់កាលទី 1 បានបញ្ចប់ ម្ចាស់សំណើគម្រោងនឹងបង្ហោះផ្សាយលើគេហទំព័រគម្រោងរបស់ខ្លួននូវឯកសារដែលបានចែករំលែកក្នុងអំឡុងពេលកិច្ចប្រជុំដំណាក់កាលទី 1 បញ្ជីឈ្មោះភាគីពាក់ព័ន្ធដែលបានទាក់ទង មតិកែលម្អបានទទួល និងវិធីដែលម្ចាស់សំណើបានពិចារណាលើមតិកែលម្អលើគម្រោង រួម

ទាំងការកែប្រែ ឬការលប់ចោលជម្រើសផ្លូវឬទីតាំងដ៏មានសក្ដានុពលដែលកំពុងពិចារណា។ ដើម្បីបញ្ជាក់ពីការបញ្ចប់ការផ្សព្វផ្សាយដំណាក់កាលទី 1 ម្ចាស់សំណើអាចនឹងបញ្ជូនបញ្ជីត្រួតពិនិត្យការបញ្ចប់ការផ្សព្វផ្សាយដំណាក់កាលទី 1 ដែលខ្លួនបានបញ្ជាក់ត្រឹមត្រូវទៅកាន់ផ្នែក DPP ។

2. <u>លក្ខខណ្ឌតម្រូវការផ្សព្វផ្សាយមុនដាក់ពាក្យសុំដំណាក់កាលទី 2</u>

ការផ្សព្វផ្សាយដំណាក់កាលទី 2 អាចចាប់ផ្តើមនៅពេលដែលកិច្ចប្រជុំផ្តោតសំខាន់ក្នុងដំណាក់កាលទី 1 ជាមួយភាគីពាក់ព័ន្ធសំខាន់ៗត្រូវបានបញ្ចប់ ហើយអាចនឹងជាមានផ្លូវឬទីតាំងដ៏មានមានសក្ដានុពលមួយចំនួនតូចដែលស្ថិតក្រោមការពិចារណា។ នៅពេលការផ្សព្វផ្សាយដំណាក់កាលទី 2 ផ្លូវឬទីតាំងដែលអាចជ្រើសយកគួរតែត្រូវបានកំណត់ និងបង្ហាញដល់សាធារណជន ក៏ដូចជាទីតាំងជំនួសបន្ថែមទៀតដែលស្ថិតក្រោមការពិចារណា។ ម្ចាស់សំណើអាចជម្រុះចោលផ្លូវ/ទីតាំងដែលមានបញ្ហាប្រឈមខ្លាំងមិនអាចសាងសង់បាន ក្តីកង្វល់រួមដែលបង្ហាញពីគ្រោះថ្នាក់ឬភាពខ្វះចន្លោះជាក់ស្តែង ឬដែលអាចកើតមានទាក់ទងនឹងផ្លូវឬទីតាំងដែលបានស្នើឡើង ដែលមិនអាចជៀសវាង កាត់បន្ថយ ឬបន្ធូរបន្ថយបាន ឬមិនគោរពតាមបទប្បញ្ញត្តិរបស់រដ្ឋនិងសហព័ន្ធ[13] មុននឹងបន្តទៅការផ្សព្វផ្សាយដំណាក់កាលទី 2 ។ ក្នុងអំឡុងពេលនៃការផ្សព្វផ្សាយដំណាក់កាលទី 2 ម្ចាស់សំណើគួរតែពណ៌នាអំពីវិធីដែលគម្រោងនេះឆ្លើយតបនឹងភាពសមស្របនៃទីតាំង និងការណែនាំអំពីការវិភាគផលប៉ះពាល់រួម បង្ហាញការប៉ាន់ប្រមាណនៃផលប៉ះពាល់បរិស្ថានទាក់ទងនឹងជម្រើសនីមួយៗ និងបង្ហាញលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់ការបដិសេធជម្រើសមួយចំនួន ឬការចាត់ថ្នាក់ជម្រើសជំនួសផ្សេងទៀត។

ការផ្សព្វផ្សាយមុនដាក់ពាក្យសុំដំណាក់កាលទី 2 នឹងត្រូវបានកំណត់លក្ខណៈដោយការផ្សព្វផ្សាយដល់សហគមន៍ទូទៅ និងយ៉ាងហោចណាស់ការប្រជុំសាធារណៈចំនួនពីរដែលរៀបចំដោយម្ចាស់សំណើ។ នៅពេលចាប់ផ្តើមការផ្សព្វផ្សាយដំណាក់កាលទី 2 ហើយបន្ទាប់ពីកិច្ចប្រជុំសាធារណៈលើកដំបូង ម្ចាស់សំណើគម្រោងនឹងតម្រូវឱ្យធ្វើការពិគ្រោះយោបល់មុនដាក់ពាក្យសុំលើកទីពីរជាមួយ MEPA និងភ្នាក់ងារអនុញ្ញាតរបស់រដ្ឋនិងមូលដ្ឋានទាំងអស់ដែលបានចូលរួមក្នុងការពិគ្រោះយោបល់ដំណាក់កាលទី 1 (លុះត្រាតែបានបដិសេធជាពិសេសពីទីភ្នាក់ងារណាមួយ) ដើម្បីទទួលបានមតិកែលម្អលើទីតាំង/ផ្លូវមួយចំនួនតូច និងជម្រើសគម្រោងផ្សេងទៀតដែលស្ថិតក្រោមការពិចារណា។ នៅពេលទទួលបានសំណើដើម្បីធ្វើការពិគ្រោះយោបល់ដំណាក់កាលទី 2 ភ្នាក់ងារ MEPA និងទីភ្នាក់ងារដែលបានអញ្ជើញផ្សេងទៀតអាចណែនាំភ្នាក់ងាររដ្ឋឬសហព័ន្ធបន្ថែមទៀតឱ្យចូលរួមក្នុងការពិគ្រោះយោបល់ដំណាក់កាលទី 2 ។ ដើម្បីជួយសម្រួលដល់ការពិគ្រោះយោបល់នេះ ម្ចាស់សំណើគួរតែផ្តល់ព័ត៌មានលម្អិតគម្រោងដូចបានបង្ហាញក្នុងដំណាក់កាលទី 1 ដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរការរចនាប្លង់គម្រោងណាមួយដែលបានកើតឡើងចាប់តាំងពីការពិគ្រោះយោបល់ដំណាក់កាលទី 1 ។ លើសពីនេះ សម្រាប់ជម្រើសនីមួយៗដែលបន្តស្ថិតនៅក្រោមការពិចារណា ម្ចាស់សំណើគួរតែផ្តល់ផែនការទីតាំងបង្ហាញស្ថានភាពដែលមានស្រាប់ និងដែលបានស្នើឡើង ប្រសិនបើមាន, បច្ចុប្បន្នភាពស្ថានភាព និង/ឬលទ្ធផលនៃការសិក្សាឬវិភាគបែបវិទ្យាសាស្ត្រណាមួយដែលកំពុងបន្តធ្វើ ឬ

---

13 លក្ខខណ្ឌតម្រូវនៃច្បាប់បម្រែបម្រួលអាកាសធាតុឆ្នាំ 2024 ផ្នែក 69T រួមបញ្ចូល "ឋានានុក្រមកាត់បន្ថយផលប៉ះពាល់ដែលត្រូវអនុវត្តអំឡុងពេលដំណើរការអនុញ្ញាតដើម្បីជៀសវាង ឬកាត់បន្ថយ ឬបន្ធូរបន្ថយផលផលប៉ះពាល់នៃការកំណត់ទីតាំងទៅលើបរិស្ថាន មនុស្ស និងគោលដៅនិងវត្ថុបំណងរបស់រដ្ឋម៉ាសាឈូសិតសម្រាប់ការកាត់បន្ថយបញ្ហាអាកាសធាតុ ការស្រូបនិងបង្ខាំងទុកកាបូន ភាពធន់ ជីវជម្រុះនិងការការពារដីធម្មជាតិនិងកសិកម្មក្នុងកម្រិតដែលអាចអនុវត្តបាន ប្រសិនបើផលប៉ះពាលមិនអាចជៀសផុត ឬមិនអាចកាត់បន្ថយបាន។"

បានបញ្ចប់ដើម្បីជូនដំណឹងដល់ភ្នាក់ងារត្រួតពិនិត្យគម្រោង, ការប៉ាន់ប្រមាណជាតួលេខលើផលប៉ះពាល់បរិស្ថាន, និងវិធានការកាត់បន្ថយផលប៉ះពាល់ជាសក្ដានុពល។ ក្នុងអំឡុងពេលពិគ្រោះយោបល់ដំណាក់កាលទី 2 ម្ចាស់សំណើគួរតែពណ៌នាអំពីវិធីដែលគម្រោងបានឆ្លើយតបទៅនឹងមតិកែលម្អពីមុនដែលទីភ្នាក់ងារនិងសាធារណៈជនបានផ្ដល់ រួមទាំងការផ្លាស់ប្ដូរចំពោះការរចនាប្លង់គម្រោងដែលបានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងមតិកែលម្អពីមុននោះ។

ម្ចាស់សំណើគម្រោងនឹងធ្វើការប្រជុំជាសាធារណៈលើកទីមួយនៅពេលជិតចាប់ផ្ដើមដំណាក់កាលទី 2 នៅពេលដែលមានផ្លូវ/ទីតាំងសក្ដានុពលមួយចំនួនតូចដែលកំពុងត្រូវបានពិចារណា ហើយម្ចាស់សំណើបានធ្វើការរចនាប្លង់វិស្វកម្មដំណាក់កាលដំបូងសម្រាប់ជម្រើសផ្លូវ/ទីតាំងគម្រោងដែលខ្លួនអាចនឹងជ្រើសយក។ ការប្រជុំជាសាធារណៈលើកទី 2 នឹងប្រព្រឹត្តទៅយ៉ាងហោចណាស់ 45 ថ្ងៃ មុនពេលម្ចាស់សំណើដាក់ពាក្យសុំទៅកាន់ក្រុមប្រឹក្សាភិបាល EFSB (សូមមើលផ្នែក B) ដើម្បីប្រមូលមតិកែលម្អលើផ្លូវ/ទីតាំងគម្រោងដែលម្ចាស់សំណើអាចនឹងជ្រើសយកដែលបានទទួលការរចនាប្លង់វិស្វកម្មបន្ថែម។

ម្ចាស់សំណើនឹងតម្រូវឱ្យបង្ហាញថាបានខិតខំប្រឹងប្រែងក្នុងអំឡុងពេលផ្សព្វផ្សាយទាំងមូលដើម្បីជូនដំណឹង ចូលរួម និងសហការជាដៃគូជាមួយមន្ត្រីថ្នាក់ក្រុង ថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋាន អង្គការសហគមន៍ ក្រុមអ្នករស់នៅនិងក្រុមអាជីវកម្ម កុលសម្ព័ន្ធ/អង្គការជនជាតិដើមភាគតិច និងក្រុមប្រឹក្សាការងារមូលដ្ឋាន។ គេរំពឹងថា ម្ចាស់សំណើគម្រោងនឹងកែសម្រួលការផ្សព្វផ្សាយឱ្យស្របតាមគម្រោង និងលក្ខណៈនៃប្រជាជនដែលអាចរងផលប៉ះពាល់។ បណ្ដាញផ្សព្វផ្សាយអាចរួមមានការចុះផ្សព្វផ្សាយតាមផ្ទះ អ៊ីមែល ការហៅទូរស័ព្ទ ការបង្ហោះផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ខិត្តប័ណ្ណបិទផ្សាយនៅក្នុងកន្លែងប្រមូលផ្ដុំសហគមន៍ ពាណិជ្ជកម្មតាមវិទ្យុ និងការទាក់ទងផ្សាយតាមបណ្ដាញទូរទស្សន៍ខ្សែកាបក្នុងស្រុក។

អ្នកគាំទ្រគម្រោងនឹងត្រូវបានលើកទឹកចិត្តឱ្យរៀបចំកិច្ចប្រជុំសាធារណៈដោយផ្ទាល់ឬតាមអនឡាញ។ ការប្រជុំសាធារណៈទាំងពីរនឹងត្រូវធ្វើឡើងនៅពេលវេលាសមស្រប និងនៅទីកន្លែងចេញចូលដែលសមាជិកសហគមន៍ប្រើប្រាស់បានជាប្រចាំ។ កិច្ចប្រជុំសាធារណៈនីមួយៗនឹងរួមបញ្ចូលពេលវេលាគ្រប់គ្រាន់សម្រាប់ការទទួលបានមតិសាធារណៈ ក៏ដូចជាការឆ្លើយសំណួររបស់ភាគីពាក់ព័ន្ធផងដែរ។ ម្ចាស់សំណើគម្រោងនឹងតម្រូវឱ្យប្រាស្រ័យទាក់ទងប្រាប់ពីកាលបរិច្ឆេទ និងពេលវេលាប្រជុំយ៉ាងហោចណាស់ 3 សប្ដាហ៍មុនការប្រជុំតាមរយៈបណ្ដាញផ្សព្វផ្សាយជាច្រើន ដែលអាចរួមបញ្ចូលនូវបញ្ជីចែកចាយព័ត៌មានអ៊ីមែលរបស់គម្រោង[14] ការផ្ញើសំបុត្រដោយផ្ទាល់ទៅអ្នករស់នៅជាប់ទីតាំងគម្រោង និងភាគីពាក់ព័ន្ធ ការបង្ហោះផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ការផ្សព្វផ្សាយតាមកាសែតបោះពុម្ពជាក្រដាស/តាមអនឡាញ និងខិតប័ណ្ណបិទផ្សាយ ក្នុងទីតាំងដែលសមាជិកសហគមន៍ប្រើប្រាស់ និងទស្សនាជាប្រចាំ។

ក្រៅពីសម្ភារៈផ្សព្វផ្សាយដែលបានចែកចាយនៅក្នុងកិច្ចប្រជុំសាធារណៈ និងក្រៅពីបញ្ជីចែកចាយអ៊ីមែលគម្រោង គេហទំព័រគម្រោងរបស់ម្ចាស់សំណើនឹងតម្រូវឱ្យបំពេញមុខងារជាប្រភពសំខាន់នៃព័ត៌មានគម្រោងថ្មីៗបំផុត។ គេហទំព័រគម្រោងនឹងរួមបញ្ចូលសេចក្ដីសង្ខេបគម្រោងជាភាសាងាយយល់, ការពិពណ៌នាគម្រោងលម្អិត, ផែនទីទីតាំង ការពិចារណាលើភាពសមស្របនៃទីតាំង និងផលប៉ះពាល់ជារួម, ផលប៉ះពាល់សុខភាព បរិស្ថាន និងសុវត្ថិភាពដែលអាចកើតមាន, ផ្លូវ/ទីតាំងដ៏មានសក្ដានុពលដែលកំពុងពិចារណា រួមទាំងផ្លូវ/ទីតាំងមិនបាន

---

14 អ្នកស្នើនឹងផ្ញើព័ត៌មានគម្រោង និងបច្ចុប្បន្នភាពព័ត៌មានជាប្រចាំទៅកាន់អ្នកដែលបានចុះឈ្មោះក្នុងបញ្ជីចែកចាយព័ត៌មានតាមអ៊ីម៉េល។ អ្នកទទួលនីមួយៗនឹងទទួលបានព័ត៌មានដូចគ្នា។ គេហទំព័រគម្រោងរបស់ម្ចាស់សំណើ នឹងរួមបញ្ចូលកន្លែងសម្រាប់ចុះឈ្មោះសម្រាប់បញ្ជីឈ្មោះនេះដោយការបញ្ចូលអាសយដ្ឋានអ៊ីម៉េល។

លប់ចេញពីការជ្រើសរើស, និងបច្ចុប្បន្នភាពព័ត៌មានបន្ទាន់ណាមួយ។ គេហទំព័រនេះក៏នឹងរួមបញ្ចូលផងដែរនូវសម្ភារៈឯកសារដែលបានចែករំលែកក្នុងអំឡុងពេលកិច្ចប្រជុំដំណាក់កាលទី 1 និងដំណាក់កាលទី 2 មតិកែលម្អពីកិច្ចប្រជុំដែលបានទទួល ព័ត៌មានទំនាក់ទំនងរបស់ម្ចាស់សំណើគម្រោង ក៏ដូចជាកន្លែងដើម្បីឱ្យអ្នកដែលអារម្មណ៍ធ្វើការចុះឈ្មោះក្នុងបញ្ជីចែកចាយព័ត៌មានតាមអ៊ីមែលជាក់លាក់នៃគម្រោង និងប្រគល់ជូនមតិយោបល់។ ក្នុងការផ្សព្វផ្សាយមុនដាក់ពាក្យសុំដំណាក់កាលទី 2 រយៈពេលផ្តល់មតិនឹងនៅតែបន្តបើកទទួលចាប់ពីកិច្ចប្រជុំសាធារណៈលើកទីមួយរហូតដល់ 30 ថ្ងៃមុនប្រគល់ការជូនដំណឹងមុនដាក់ពាក្យសុំទៅកាន់ក្រុមប្រឹក្សាភិបាល EFSB ។ ម្ចាស់សំណើគម្រោងនឹងតម្រូវឱ្យធ្វើបច្ចុប្បន្នភាពគេហទំព័រគម្រោងជាប្រចាំ និងផ្តល់បញ្ជីចែកចាយព័ត៌មានគម្រោងដែលមានបច្ចុប្បន្នភាពព័ត៌មានប្រចាំត្រីមាស រួមមានរបាយការណ៍វឌ្ឍនភាពថ្មីៗ ការរំឭកពីវិធីដែលសាធារណជនអាចចូលរួម និងពេលវេលាប៉ាន់ស្មានសម្រាប់ការដាក់ពាក្យស្នើសុំទៅកាន់ក្រុមប្រឹក្សាភិបាល EFSB ។

របៀបវារៈនៃកិច្ចប្រជុំ បទបង្ហាញ និងសម្ភារៈផ្សេងទៀតនឹងត្រូវបានបកប្រែ ហើយម្ចាស់សំណើនឹងផ្តល់ការបកប្រែប្រេដញផ្ទាល់មាត់សម្រាប់អំឡុងពេលកិច្ចប្រជុំសាធារណៈដំណាក់កាលទី 2 ជាភាសាដែលបានកំណត់តាមផែនប្រើប្រាស់ភាសារបស់ក្រុមប្រឹក្សាភិបាល EFSB បច្ចុប្បន្ន ("LAP")។ ការបកប្រែឯកសារ និងការបកប្រែផ្ទាល់មាត់នឹងត្រូវបានផ្តល់ជូនជាភាសាផ្សេងទៀតតាមការស្នើសុំ។ ឯកសារផ្សព្វផ្សាយ និងគេហទំព័រគម្រោងក៏នឹងរួមបញ្ចូលព័ត៌មានអំពីវិធីស្នើសុំសេវាបកប្រែឯកសារ និង/ឬ ការបកស្រាយផ្ទាល់មាត់ផងដែរ។ សេវាកម្មប្រើប្រាស់ភាសាទាំងអស់ដែលទាក់ទងនឹងការផ្សព្វផ្សាយមុនដាក់ពាក្យសុំ នឹងត្រូវបានម្ចាស់គម្រោងរៀបចំ និងបង់ប្រាក់។

ដើម្បីបញ្ជាក់ពីការបញ្ចប់ការផ្សព្វផ្សាយដំណាក់កាលទី 2 ម្ចាស់សំណើនឹងប្រគល់តារាងត្រួតពិនិត្យការបញ្ចប់ការផ្សព្វផ្សាយដំណាក់កាលទី 2 ដែលខ្លួនបញ្ជាក់ត្រឹមត្រូវទៅឱ្យផ្នែក DPP មុនពេលដាក់ពាក្យស្នើសុំគម្រោងទៅកាន់ក្រុមប្រឹក្សាភិបាល EFSB ។

<u>B. តម្រូវការការជូនដំណឹងជាមុន (ការជូនដំណឹងអំពីបំណងក្នុងការដាក់ ពាក្យស្នើសុំ)</u>

សម្រាប់ទីតាំងទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំ ម្ចាស់សំណើនឹងតម្រូវឱ្យប្រគល់លិខិតជូនដំណឹងមុនដាក់ពាក្យសុំជូនដល់ក្រុមប្រឹក្សាភិបាល EFSB ក្នុងរយៈពេលមិនក្រោម 90 ថ្ងៃ និងមិនលើសពី 120 ថ្ងៃមុនពេលដាក់ពាក្យស្នើសុំទៅកាន់ក្រុមប្រឹក្សាភិបាល EFSB ។ ក្នុងករណីទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូច ម្ចាស់សំណើ ត្រូវដាក់លិខិតជូនដំណឹងមុនដាក់ពាក្យសុំក្នុងរយៈពេលមិនក្រោម 90 ថ្ងៃមុនពេលដាក់ពាក្យស្នើសុំទៅកាន់ក្រុមប្រឹក្សាភិបាល EFSB ។ ប្រសិនបើម្ចាស់សំណើមិនបានដាក់ពាក្យសុំត្រឹមកាលបរិច្ឆេទដែលបានដាក់បញ្ចូលក្នុងសេចក្តីជូនដំណឹងមុនដាក់ពាក្យសុំនោះ ម្ចាស់សំណើត្រូវប្រគល់ជូនសាជាថ្មីនូវការជូនដំណឹងមុនដាក់ពាក្យសុំនោះ។ ប្រសិនបើថ្ងៃផុតកំណត់នៃការជូនដំណឹងមុនដាក់ពាក្យសុំលើកទីពីរបានកន្លងផុតទៅ ហើយពាក្យសុំសម្រាប់គម្រោងដែលបានស្នើមិនទាន់បានដាក់ទេនោះ ម្ចាស់សំណើអាចនឹងតម្រូវឱ្យធ្វើការផ្សព្វផ្សាយបន្ថែម មុនពេលអាចប្រគល់ការជូនដំណឹងមុនដាក់ពាក្យសុំជូនដល់ក្រុមប្រឹក្សាភិបាល EFSB ។

ការជូនដំណឹងមុនដាក់ពាក្យសុំនឹងរាយបញ្ជីព័ត៌មានលម្អិតអំពីគម្រោង រួមទាំងសេចក្តីសង្ខេបគម្រោងជាភាសាងាយយល់ ឈ្មោះគម្រោង ទីតាំង ផែនទី ព័ត៌មានរបស់បុគ្គលទំនាក់ទំនងដែលបានកំណត់ និងតំណភ្ជាប់ទៅកាន់គេហទំព័រគម្រោង។ លើសពីនេះ វានឹងរួមបញ្ចូលព័ត៌មានអំពីកាលបរិច្ឆេទដាក់ស្នើគម្រោងដែលបានរំពឹងទុក ព័ត៌មានលម្អិតនៃកិច្ចប្រជុំសាធារណៈដែលធ្វើឡើង ឬបានគ្រោងទុក ថេរវេលានៃរយៈពេលផ្តល់មតិជាសាធារណៈ ភាសាដែលនឹងមានការបកប្រែឯកសារ និងការបកប្រែផ្ទាល់មាត់ និងវិធីស្នើសុំសេវាប្រើប្រាស់ភាសា។ ការជូនដំណឹងជាមុននៃការដាក់ឯកសារក៏នឹងមាននៅលើគេហទំព័ររបស់ម្ចាស់សំណើ រួមជាមួយនឹង

សំណៅដែលបានបកប្រែដែលបានកំណត់ស្របតាមផែនការ LAP របស់ក្រុមប្រឹក្សាភិបាល EFSB បច្ចុប្បន្ន។

C- ឯកសារដែលត្រូវដាក់ជូន (ដាក់ឯកសារ) រួមជាមួយនឹងការជូនដំណឹងមុនដាក់ពាក្យសុំ

ម្ចាស់សំណើគម្រោងនឹងតម្រូវឱ្យដាក់ឯកសារខាងក្រោមទៅកាន់ក្រុមប្រឹក្សាភិបាល EFSB រួមជាមួយនឹងការជូនដំណឹងមុនដាក់ពាក្យសុំ៖

- ការបញ្ជាក់ដោយខ្លួនឯងថាបានបំពេញតាមលក្ខខណ្ឌតម្រូវនៃការផ្សព្វផ្សាយដំណាក់កាលទី 1 ទាំងអស់ ស្ថានភាពនៃកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយដំណាក់កាលទី 2 និងបញ្ជាក់ថាការប្រជុំមុនដាក់ពាក្យសុំរវាងម្ចាស់សំណើគម្រោង បុគ្គលិក DPP និងបុគ្គលិក OEJE ត្រូវបានរៀបចំឡើងដូចបានកំណត់សម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំនិងខាតតូច។
- របាយការណ៍ស្តីពីកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយ និងការចូលរួមរបស់សាធារណជន រួមមាន៖
    - ព័ត៌មានស្តីពីសម្ភារៈឯកសារផ្សព្វផ្សាយដែលបានបង្កើតឡើង អ្នកទទួលការផ្សព្វផ្សាយ រួមទាំងកាលបរិច្ឆេទនិងវិធីទំនាក់ទំនង ឧបករណ៍និងសកម្មភាពដែលទាក់ទាញនិងលើកទឹកចិត្តឱ្យមានមតិចូលរួមពីអង្គការតាមសហគមន៍ អង្គការកុលសម្ព័ន្ធ/ជនជាតិដើមភាគតិច ក្រុមអ្នករស់នៅ និងអង្គភាពមូលដ្ឋានផ្សេងទៀត និងតំណាងទីភ្នាក់ងាររដ្ឋ។
    - របៀបវារៈសម្រាប់ការប្រជុំសហគមន៍ដែលបានរៀបចំឡើង សម្ភារៈឯកសារដែលបានចែកចាយ និងកំណត់ហេតុកិច្ចប្រជុំដែលរួមមានកង្វល់ សំណួមពរ និងជម្រើស/ការកែប្រែទីតាំងដែលបានបញ្ជាក់ប្រាប់។
    - ឧបសម្ព័ន្ធដែលសង្ខេបមតិយោបល់មុនដាក់ពាក្យសុំដែលបានទទួល វិធីសាស្ត្រដែលម្ចាស់សំណើគម្រោងបានពិចារណាលើមតិយោបល់នៅក្នុងការរចនាប្លង់គម្រោងរបស់ខ្លួន។ ការកែប្រែការរចនាប្លង់គម្រោងសំខាន់ៗគួរតែត្រូវបានកំណត់យ៉ាងច្បាស់។
    - ភាពជាដៃគូណាមួយដែលត្រូវបានបង្កើតឡើងជាមួយភាគីពាក់ព័ន្ធតាមមូលដ្ឋានដើម្បីផ្តល់មតិចូលរួមក្នុងនាមជាស្ថាប័នទីប្រឹក្សា និង
    - សំណើអត្ថប្រយោជន៍សហគមន៍ត្រូវបានបង្កើតឡើង ឬកិច្ចព្រមព្រៀងអត្ថប្រយោជន៍សហគមន៍ដែលបានបង្កើតឡើង ប្រសិនបើអាចអនុវត្តបាន និង
- ការបញ្ជាក់ដោយខ្លួនឯងពីម្ចាស់សំណើរ និងទីក្រុងដែលរងផលប៉ះពាល់ដែលភាគីទាំងអស់បានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីចរចាទាក់ទងនឹងទិដ្ឋភាពស្នូលនៃទីតាំងដែលបានស្នើ -- ការរចនាប្លង់/ទីតាំងជំនួស ការកាត់បន្ថយផលប៉ះពាល់គម្រោង ឬអត្ថប្រយោជន៍ទូទាត់សំណង សេវាសុវត្ថិភាពសាធារណៈ ឬស្តង់ដាឧបករណ៍។

## IV. សំណើសុំមតិយោបល់

1. តើមានជម្រើសទីតាំង/ផ្លូវចំនួនប៉ុន្មានដែលជាធម្មតាត្រូវបានពិចារណាសម្រាប់ប្រភេទគម្រោងខុសៗគ្នា (ឧ. ថាមពលពន្លឺព្រះអាទិត្យ ខ្យល់ ការស្តុកទុកថាមពលអាគុយ)? ហើយតើនៅក្នុងដំណាក់កាលណានៃវដ្តអភិវឌ្ឍគម្រោងគឺជាជម្រើសទីតាំង/ផ្លូវរបស់គម្រោងដែលស្ថិតក្នុងការពិចារណា ដែលរួចរាល់ក្នុងការចែករំលែកបានជាមួយភាគីពាក់ព័ន្ធ ក្នុងការផ្សព្វផ្សាយដំណាក់កាលទី 1?

2. តើមានអ្នកមានសំណូមពរបន្ថែមអ្វីខ្លះ ដើម្បីធ្វើឲ្យភាគីពាក់ព័ន្ធចូលរួម ជាពិសេសក្នុងអំឡុងការផ្សព្វផ្សាយដំណាក់កាលទី 1 ដើម្បីជូនដំណឹងអំពីការជ្រើសរើសជម្រើសនៃទីតាំង/ផ្លូវ?

3. [ចំពោះទីភ្នាក់ងារ] តើការប្រជុំជាមួយ MEPA និងទីភ្នាក់ងាររដ្ឋផ្សេងទៀតគួរតែប្រព្រឹត្តទៅក្នុងអំឡុងពេលផ្សព្វផ្សាយដំណាក់កាលទី 1 (នៅពេលមានជម្រើសទីតាំង/ផ្លូវដែលមានសក្តានុពលជាច្រើន) ឬក្នុងដំណាក់កាលទី 2 នៅពេលដែលមានជម្រើសតិចតួច ឬក្នុងដំណាក់កាលទាំងពីរដែរឬទេ? សូមបញ្ជាក់ភ្នាក់ងារដែលគួរពិគ្រោះយោបល់ក្នុងដំណាក់កាលនីមួយៗ។

4. តើនៅពេលណាដែលការចូលរួមមុនដាក់ពាក្យសុំគួរតែផ្លាស់ប្តូរពីដំណាក់កាលទី 1 (ការផ្សព្វផ្សាយគោលដៅទៅកាន់ភាគីពាក់ព័ន្ធសំខាន់ៗ) ទៅដំណាក់កាលទី 2 (ការចែករំលែកព័ត៌មានកាន់តែទូលំទូលាយទៅដល់សហគមន៍ទូទៅ)? តើគួរតែផ្អែកលើចំនួនផ្លូវ/ទីតាំងដែលកំពុងពិចារណា ឬកត្តាពាក់ព័ន្ធ ផ្សេងទៀតដែរឬទេ?

5. ពង្រាងសំណើគម្រោងនេះណែនាំឱ្យលក្ខខណ្ឌតម្រូវការផ្សព្វផ្សាយដំណាក់កាលទី 2 សម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំ គួរចាប់ផ្តើមយ៉ាងហោចណាស់ 9 ខែ មុនពេលម្ចាស់សំណើប្រគល់ការជូនដំណឹងមុនដាក់ពាក្យសុំជូនដល់ក្រុមប្រឹក្សាភិបាល EFSB ។ សម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូច នេះគួរតែចាប់ផ្តើមយ៉ាងហោចណាស់ 6 ខែមុន។ តើពេលវេលានេះចាំបាច់ត្រូវកែប្រែទេ?

6. តើមានលក្ខខណ្ឌតម្រូវមុនដាក់ពាក្យសុំបន្ថែមដែលគួរត្រូវបានពិចារណាដើម្បីកែលម្អតម្លាភាព និងធានាថាភាគីពាក់ព័ន្ធដែលមានផលប៉ះពាល់អាចមានឱកាសក្នុងការផ្តល់មតិចូលរួមជាពិសេសជុំវិញការជ្រើសរើសផ្លូវ/ទីតាំងដែរឬទេ?

7. តើប្រភេទ ឬបរិមាណនៃការផ្សព្វផ្សាយរបស់អ្នកដាក់ពាក្យសុំទៅកាន់សហគមន៍គួរប្រែប្រួលអាស្រ័យលើប្រភេទគម្រោង ទំហំ ឬទីតាំងដែរឬទេ?

8. តើមានដំណាក់កាលសំខាន់ណាមួយក្នុងវដ្តនៃការអភិវឌ្ឍគម្រោងនេះដែរឬទេ នៅពេលដែលការរចនាប្លង់គម្រោងមានខ្លឹមសារគ្រប់គ្រាន់សម្រាប់មតិចូលរួមប្រកបដោយអត្ថន័យ ប៉ុន្តែជម្រើសផ្លូវ/ទីតាំងនៅតែអាចកែប្រែបានដោយងាយផ្អែកលើមតិចូលរួមនេះ?

9. តើរយៈពេលដែលបានស្នើឡើងដើម្បីឱ្យម្ចាស់សំណើគម្រោងប្រគល់ការជូនដំណឹងមុនដាក់ពាក្យសុំជូនដល់ក្រុមប្រឹក្សាភិបាល EFSB សម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតធំនិងខ្នាតតូច មានភាពគ្រប់គ្រាន់ដែរឬទេ?

10. តើបណ្តាញផ្សព្វផ្សាយ និងការអនុវត្តការចូលរួមមួយណាមានប្រសិទ្ធភាពបំផុត ហើយអាចត្រូវបានប្រើប្រាស់ដោយម្ចាស់សំណើគម្រោងដើម្បីជូនដំណឹងដល់សហគមន៍ដែលរងផលប៉ះពាល់ដោយគម្រោងមួយដែរឬទេ?

11. តើក្រុមប្រឹក្សាភិបាល EFSB គួរតែតម្រូវឱ្យម្ចាស់សំណើគម្រោងទាំងអស់ពិភាក្សាអំពីកិច្ចព្រមព្រៀងអត្ថប្រយោជន៍សហគមន៍ជាមួយអ្នកតំណាងថ្នាក់ក្រុងដែរឬទេ?

12. តើគួរបែងចែងពេលវេលានៃដំណើរការមុនដាក់ពាក្យសុំទៅតាមប្រភេទបច្ចេកវិទ្យាដែរឬទេ? បើមាន សូមរៀបរាប់។

13. តើពេលវេលាដំណើរការមុនដាក់ពាក្យសុំសម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូចដែលជ្រើសរើសស្វែងរកលិខិតអនុញ្ញាតរួមពីក្រុមប្រឹក្សាភិបាល EFSB មានលក្ខណៈដូចគ្នាទៅនឹងពេលវេលាមុនដាក់ពាក្យសុំសម្រាប់ទីតាំងហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាតខ្នាតតូចដែរឬទេ?